UNITED NATIONS
CAMBODIA

# ការគាំទ្ររបស់អង្គការសហប្រជាជាតិនៅកម្ពុជា ដល់កម្មករកាត់ដេរ ក្នុងការឆ្លើយតបចំពោះជំងឺកូវីដ ១៩
## ឯកសារព័ត៌មានទី ៧
## ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០២១

ការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់ឧស្សាហកម្មកាត់ដេរនៅកម្ពុជា។ ការរាតត្បាតជាសកលនេះ ព្រមទាំងកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្អង់ល្បឿននៃការឆ្លងរាលដាលនៃវីរុសនេះ នាំឱ្យរោងចក្រជាច្រើនត្រូវបិទទ្វារ និងមានការផ្អាក និងព្យួរការងារកម្មករ ដោយពុំទទួលបានប្រាក់ឈ្នួល ដែលបង្កផលប៉ះពាល់ដល់ជីវិត និងជីវភាពរស់នៅរបស់កម្មករវិស័យកាត់ដេរប្រមាណ ៩00 000 នាក់។ កម្លាំងពលកម្មនៅក្នុងវិស័យកាត់ដេរ ៨0% ជាស្ត្រី ហើយពួកគេត្រូវរងផលប៉ះពាល់លើសលប់ ដោយសារការរាតត្បាតជាសកលនេះ ដែលធ្វើឱ្យវិសមភាពកាន់តែមានការកើនឡើង និងធ្វើឱ្យពួកគេធ្លាក់ខ្លួនកាន់តែជ្រៅទៅក្នុងភាពក្រីក្រ។ មានកត្តាចំនួន ៣ ដែលបង្កហានិភ័យខ្ពស់នាំឱ្យមានការឆ្លងជំងឺកូវីដ-១៩ ដូចជា ទីតាំងដែលមានមនុស្សកកកុញ ការនៅកៀកគ្នា និងទីតាំងបិទជិត (3C)។ កម្មករកាត់ដេរច្រើនតែរស់នៅ ធ្វើការ និងធ្វើដំណើរ នៅក្នុងបរិបទ 3C ខាងលើនេះ ដែលនាំឱ្យពួកគេពិបាកនឹងរក្សាគម្លាតសុវត្ថិភាព និងធ្វើឱ្យពួកគេកាន់តែប្រឈមនឹងការឆ្លងជំងឺកូវីដ-១៩ ក្នុង និងក្រៅកន្លែងធ្វើការរបស់ពួកគេ។

ប្រព័ន្ធអង្គការសហប្រជាជាតិនៅកម្ពុជាស្វាគមន៍កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលផ្តល់អាទិភាពការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនកម្មករកម្មការនីក្នុងវិស័យកាត់ដេរ។ ចាប់តាំងពីខែមេសា ឆ្នាំ ២០២០ មក រាជរដ្ឋាភិបាលបានផ្តល់ឱ្យកម្មករកាត់ដេរ ដែលត្រូវបានព្យួរពីការងារដោយសារការរាតត្បាតជាសកលនេះ នូវប្រាក់ឧបត្ថម្ភចំនួន ៤០ ដុល្លារក្នុងមួយខែ។ កាលពីខែមិថុនា ឆ្នាំ ២០២១ ថ្មីៗនេះ រាជរដ្ឋាភិបាលបានអនុម័តលើកម្មវិធីផ្តល់ជំនួយសាច់ប្រាក់សម្រាប់ស្ថានភាពអាសន្ន ក្រោយបិទខ្ទប់ ដែលផ្តល់ជូនតែមួយដង ដែលនឹងផ្តល់ជាប្រយោជន៍ដល់កម្មករកាត់ដេរ។ បើទោះជារដ្ឋាភិបាលកំពុងផ្តល់ការគាំទ្របែបនេះក៏ដោយ ប្រព័ន្ធអង្គការសហប្រជាជាតិនៅកម្ពុជាមានការព្រួយបារម្ភពីផលប៉ះពាល់យូរអង្វែង ដោយសារការរាតត្បាតជាសកល និងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺនេះ មកលើសិទ្ធិសង្គមកិច្ច និងសេដ្ឋកិច្ចរបស់កម្មករកាត់ដេរ។ ការបាត់បង់ការងារ និងការថយចុះចំណូលធ្វើឱ្យមនុស្សជាច្រើននាក់ជួបការលំបាកក្នុងការបំពេញតម្រូវការចាំបាច់ជាមូលដ្ឋានរបស់ពួកគេ និងធ្វើឱ្យកម្មករខ្វះបុលសម្រាប់ទប់ទល់នឹងការលំបាករបស់ពួកគេ។ កម្មករជាច្រើននាក់ពុំមានសំណាញ់សុវត្ថិភាពសង្គមគ្រប់គ្រាន់ ដូចជាអត្ថប្រយោជន៍សម្រាប់និកម្មភាព[1] នោះឡើយ ដែលធ្វើឱ្យពួកគេងាយនឹងធ្លាក់ចូលទៅក្នុងភាពក្រីក្រ និងអាចថែមទាំងគ្រោះអត់ឃ្លានទៀតផង។ ផលប៉ះពាល់នេះបន្តកើតមានលើគ្រួសាររបស់កម្មករកាត់ដេរ ព្រមទាំងអ្នកប្រកបរបរក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ នៅជុំវិញរោងចក្រផងដែរ។ កាលពីឆ្នាំ ២០១៩ ឧស្សាហកម្មកាត់ដេររួមចំណែកប្រមាណ ១១% នៃ

[1] បច្ចុប្បន្ននេះ នៅកម្ពុជា ពុំមានរបបធានារ៉ាប់រងនិកម្មភាពនោះឡើយ ហើយកម្មករនិយោជិតពុំបានទទួលអត្ថប្រយោជន៍ផ្នែកគាំពារសង្គម នៅពេលដែលពួកគេបាត់បង់ការងារនោះដែរ។ ប៉ុន្តែ កន្លងមកមានការដាក់ឱ្យអនុវត្តនូវវិធានការ ដើម្បីឆ្លើយតបចំពោះបញ្ហាបាត់បង់ប្រាក់ចំណូល ដោយសារការបិទរោងក្រនៅពេលដែលមានការរាតត្បាតជាសកលនៃជំងឺកូវីដ ១៩ ប៉ុន្តែវិធានការទាំងនេះ ជារឿយៗ ពុំមានភាពគ្រប់គ្រាន់នោះឡើយ។ កម្មករកាត់ដេរជាច្រើននាក់ត្រូវបានផាត់ចេញពីអត្ថប្រយោជន៍មួយចំនួន ព្រោះថាពួកគេមានការងារធ្វើនៅក្នុងវិស័យក្នុងប្រព័ន្ធ និងមិនត្រូវបានគេចាត់ទុកថាជាជនក្រីក្រ។

ផសស។ ប៉ុន្តែ ចាប់តាំងពីការរាតត្បាតជាសកលនេះមក ការនាំចេញសម្លៀកបំពាក់ថតចុះប្រមាណ ៩,៩% ដែលនាំឱ្យថយចុះ ៣,៤% នៃផសសក្នុងឆ្នាំ ២០២០។ ប្រព័ន្ធអង្គការសហប្រជាជាតិក៏បារម្ភផងដែរ អំពីស្ថានភាពនៅតាមមណ្ឌលចត្តាឡីស័ក សម្រាប់កម្មករកាត់ដេរ នៅពេលដែលពួកគេធ្វើតេស្តរកឃើញថាវិជ្ជមាន រួមនឹងការខ្វះព័ត៌មាន សម្ភារៈអនាម័យ និងឧបករណ៍ការពារខ្លួន។

ជាការឆ្លើយតប ប្រព័ន្ធអង្គការសហប្រជាជាតិ កំពុងធ្វើការងារជាមួយនឹងអាជ្ញាធរជាតិ និងតួអង្គពាក់ព័ន្ធ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានចំពោះមុខ ដែលកើតឡើងដោយសារការរាតត្បាតជាសកលនេះ និងកសាងនូវឧស្សាហកម្មកាត់ដេរ ដែលកាន់តែមានចីរភាព និងកាន់តែមានភាពធន់សម្រាប់រយៈពេលវែង។ តាមរយៈការផ្តល់ជំនួយបច្ចេកទេស និងការស្វែងរកការគាំទ្រ អង្គការសហប្រជាជាតិកំពុងផ្តល់អាទិភាពដល់ការការពារសុខភាព ការងារ និងប្រាក់ចំណូលរបស់កម្មករកាត់ដេរ ក៏ដូចជាលើកកម្ពស់ជីវភាពរស់នៅ ជំរុញឱ្យមានការបន្តនិរន្តរភាពអាជីវកម្ម និងបង្កើនភាពប្រកួតប្រជែងនៃឧស្សាហកម្មកាត់ដេរ។ អង្គការសហប្រជាជាតិផ្តល់ការគាំទ្រដល់គណៈកម្មាធិការទ្វេភាគី (ដែលមានការចូលរួមពីកម្មករ និងអ្នកគ្រប់គ្រង) នៅតាមរោងចក្រនានា[2] ក៏ដូចជាដល់យន្តការត្រីភាគី ដែលមានការចូលរួមពីរដ្ឋាភិបាល និយោជក និងកម្មការនិយោជិតនៅថ្នាក់ជាតិ ដើម្បីជំរុញឱ្យមានការសន្ទនាអំពីតម្រូវការនៅក្នុងវិស័យនេះ។ កិច្ចសន្ទនាត្រីភាគី ក៏លើកទឹកចិត្តឱ្យមានការបង្កើនការសហការគ្នា ដើម្បីស្វែងរកដំណោះស្រាយក្នុងអំឡុងពេល ដែលកំពុងមានការរាតត្បាតជាសកលនេះផងដែរ។ ក្រុមហ៊ុនម៉ាកយីហោអន្តរជាតិដែលបញ្ជាទិញពីកម្ពុជា[3] គឺជាដៃគូសំខាន់របស់អង្គការសហប្រជាជាតិនៅក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន នៅក្នុងវិស័យកាត់ដេរ។

ដើម្បីឈ្វេងយល់ឱ្យកាន់តែច្បាស់ពីស្ថានភាពរបស់កម្មករកាត់ដេរ ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ អង្គការសហប្រជាជាតិបានធ្វើការសម្ភាសជាមួយនឹងកម្មករកាត់ដេរជិត ៤០០ នាក់ កាលពីខែឧសភា ឆ្នាំ ២០២០ និងបានធ្វើការសម្ភាសម្តងទៀតនៅក្នុងខែឧសភា/មិថុនា ឆ្នាំ ២០២១ ជាមួយនឹងកម្មករកាត់ដេរចំនួន ៣៧០ នាក់ ដើម្បីឈ្វេងយល់ពីការបារម្ភ ក៏ដូចជាបញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ពួកគេ។ ការបារម្ភដែលកម្មករលើកឡើងញឹកញាប់ជាងគេ រួមមាន ការបារម្ភដែលពាក់ព័ន្ធនឹងហិរញ្ញវត្ថុផ្ទាល់ខ្លួន ដូចជា ការពុំមានលទ្ធភាពសងបំណុល ក៏ដូចជា ការបារម្ភពីសុវត្ថិភាព និងសុខភាពចំពោះមុខរបស់គ្រួសារពួកគេ។ កម្មករនិយោជិតជួបប្រទះនឹងការលំបាកមួយចំនួនក្នុងការរាយការណ៍ពីរោគសញ្ញាដូចជា ការខ្លាចការធ្វើចត្តាឡីស័ក និងការបាត់បង់ចំណូលជាដើម។ ការស្រាវជ្រាវបន្ថែមទៀតបង្ហាញថា បើទោះជាមានការបារម្ភធ្ងន់ធ្ងរពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ ក៏ដោយ កម្មករមានការលំបាកក្នុងការអនុវត្តតាមវិធានការការពារ។ ដោយហេតុនេះហើយទើបអង្គការសហប្រជាជាតិនឹងអនុវត្តយុទ្ធនាការផ្លាស់ប្តូរឥរិយាបថជុំវិញជំងឺកូវីដ-១៩ ដែលនឹងផ្តល់ព័ត៌មានលម្អិតអំពីវិធានការការពារ និងវិធានការកាត់បន្ថយហានិភ័យនៅក្នុងឧស្សាហកម្មកាត់ដេរ និងសហគមន៍ដែលនៅជុំវិញ។

ដើម្បីការពារកម្មករវិស័យកាត់ដេរ និងសុវត្ថិភាពសាធារណៈ អង្គការសហប្រជាជាតិបានផ្តួចផ្តើមឱ្យមានការវាយតម្លៃហានិភ័យនៅក្នុងវិស័យកាត់ដេរ ដើម្បីត្រៀមរៀបចំរោងចក្រឱ្យចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួនឡើងវិញ ក្រោយ

---

[2] កម្មវិធីការងារកាន់តែប្រសើររបស់អង្គការអន្តរជាតិខាងការងារ (ILO)-និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ធ្វើការនៅតាមសហគ្រាសក្នុងប្រទេសចំនួន ១០ ដើម្បីគាំទ្រដល់ការកែលម្អលក្ខខណ្ឌការងារនៅតាមរោងចក្រ តាមរយៈការរៀបចំឱ្យមានជាកិច្ចពិគ្រោះយោបល់រវាងអ្នកគ្រប់គ្រង និងតំណាងកម្មករនិយោជិត (គណៈកម្មាធិការទ្វេភាគី)។ នៅកម្ពុជា កម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជាធ្វើការងារជាមួយនឹងគណៈកម្មាធិការទ្វេភាគីនៅក្នុងរោងចក្រប្រមាណជា ២០០ ដើម្បីជំរុញឱ្យមានកិច្ចសន្ទនាសង្គមរវាងភាគីពាក់ព័ន្ធនានា។

[3] ក្រោមកម្មវិធីការងារកាន់តែប្រសើរ ដែលជាកម្មវិធីអនុវត្តនៅទូទាំងសកលលោក កម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា បានរៀបចំកិច្ចព្រមព្រៀងភាពជាដៃគូរជាមួយនឹងក្រុមហ៊ុនម៉ាកយីហោអន្តរជាតិប្រមាណជា ៤០។

ពេលបិទខ្ទប់កាលពីខែឧសភា ឆ្នាំ ២០២១។ នេះមានគោលបំណងដាក់ឱ្យអនុវត្តវិធានការកាត់បន្ថយហានិភ័យជាមុនសិនមុនពេលបើកដំណើរការឡើងវិញ ដោយប្រើប្រាស់វិធីសាស្ត្រពហុវិស័យ និងមានការចូលរួមទូលំទូលាយពីសហគមន៍ ក្នុងនោះនឹងមានការជំរុញឱ្យមានការចូលរួមពីវិស័យធុរកិច្ច ដើម្បីស្វែងរកដំណោះស្រាយដែលកាន់តែមានសុវត្ថិភាព និងផលិតភាព នៅពេលដំណើរការអាជីវកម្ម ក្រោម "គន្លងថ្មី"។ អង្គការសហប្រជាជាតិកំពុងធ្វើការងាររួមគ្នា ជាមួយនឹងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបង្កើនការយល់ដឹងអំពីវិធានការកាត់បន្ថយហានិភ័យជំងឺកូវីដ-១៩ នៅតាមរោងចក្រនៅក្នុងរាជធានីភ្នំពេញ និងខេត្តជុំវិញ។ កន្លងមក គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីវិធានការកាត់បន្ថយហានិភ័យជំងឺកូវីដ-១៩ នៅតាមកន្លែងធ្វើការ រោងចក្រ និងសហគ្រាស ត្រូវបានដាក់ជូនរដ្ឋាភិបាលដើម្បីពិនិត្យ។ លើសពីនេះ បញ្ជីត្រួតពិនិត្យដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិផ្តោតលើការការពារ និងការកាត់បន្ថយហានិភ័យជំងឺកូវីដ-១៩ នៅកន្លែងធ្វើការ និងគោលការណ៍ណែនាំស្តីពី រើសអើង និងការមាក់ងាយពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ ត្រូវបានបកប្រែ និងចែកជូនរោងចក្រផងដែរ។ លើសពីនេះ ក៏មានការផ្តល់អនុសាសន៍ជូនរដ្ឋាភិបាលអំពីរបៀបឆ្លើយតបចំពោះករណីវិជ្ជមានកូវីដ-១៩ នៅតាមរោងចក្រផងដែរ។ អង្គការសហប្រជាជាតិក៏បានផ្សព្វផ្សាយព័ត៌មានយ៉ាងទូលំទូលាយដល់រោងចក្រកាត់ដេរ និងកម្មករកាត់ដេរ ដោយលើកទឹកចិត្តឱ្យពួកគេអនុវត្តតាមវិធានការប្រុងប្រយ័ត្ន ដើម្បីកាត់បន្ថយការឆ្លង និងការចម្លងជំងឺកូវីដ-១៩។

ជាផ្នែកមួយនៃកម្មវិធីផ្តល់ជំនួយបច្ចេកទេសផ្តោតលើវិស័យកាត់ដេរ អង្គការសហប្រជាជាតិបានផ្តល់ការគាំទ្រនូវកម្រិតរោងចក្រ និងកម្រិតវិស័យ ដូចជាការវាយតម្លៃដែលត្រូវបានកំណត់ថាជាកាតព្វកិច្ចសម្រាប់រោងចក្រ ការអភិវឌ្ឍសមត្ថភាព សិក្ខាសាលាតាមប្រព័ន្ធអនឡាញ និងរៀបចំឱ្យមានជាកិច្ចប្រជុំរវាងគូអង្គពាក់ព័ន្ធនៅក្នុងឧស្សាហកម្ម ដើម្បីពិភាក្សាពីបញ្ហានានា ពាក់ព័ន្ធនឹងវិស័យកាត់ដេរនៅកម្ពុជា។ ប្រព័ន្ធអង្គការសហប្រជាជាតិក៏បានចូលរួមសហការជាបន្តបន្ទាប់ជាមួយនឹងរោងចក្រ និងគូអង្គពាក់ព័ន្ធនៅក្នុងឧស្សាហកម្ម ដើម្បីពិភាក្សាពីបញ្ហានានា ដូចជាសុខភាព និងសុវត្ថិភាពការងារ (OSH) សមភាពយេនឌ័រ ការការពារជំងឺកូវីដ-១៩ ការត្រៀមបង្ការឆ្លើយតបចំពោះស្ថានភាពអាសន្ន ការគ្រប់គ្រងវិបត្តិ ការប្រាស្រ័យទាក់ទងជាមួយនឹងកម្មករ និងអ្នកដឹកនាំ ច្បាប់ការងារ ប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថល ភាពអនុលោមតាមច្បាប់ប្រកបដោយចីរភាព និងអនាគតនៃឧស្សាហកម្មនេះនៅកម្ពុជា។ ចាប់តាំងពីដើមឆ្នាំ ២០២១ មក អង្គការសហប្រជាជាតិបានសម្របសម្រួលកិច្ចប្រជុំជាង ៤៥៥ លើកជាមួយនឹងគណៈកម្មាធិការចម្រុះនៅកម្រិតរោងចក្រដែលមានសមាសភាពជាកម្មករ និងអ្នកគ្រប់គ្រងក្នុងរោងចក្រប្រមាណជាង ២០០ (ការពិនិត្យតាមប្រព័ន្ធអនឡាញចំនួន ២៨៩ លើក និងការពិនិត្យផ្ទាល់ចំនួន ១៦៦ លើក)។ ការបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញជាង ៤០ លើក ផ្តោតលើប្រធានបទផ្សេងៗ សម្រាប់កម្មកររោងចក្រ និងអ្នកគ្រប់គ្រងក៏ត្រូវបានធ្វើឡើងផងដែរ។ អង្គការសហប្រជាជាតិបន្តធ្វើការយ៉ាងជិតស្និតជាមួយនឹងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាគមន៍កាត់ដេរនៅកម្ពុជា (GMAC) និងសហជីពជុំវិញបញ្ហាសំខាន់ៗទាំងនេះ។

អង្គការអន្តរជាតិខាងការងារ (ILO) ដែលជាទីភ្នាក់ងារសហប្រជាជាតិមានភារកិច្ចធ្វើការវាយតម្លៃលក្ខខណ្ឌការងារ និងធានាភាពអនុលោមតាមស្តង់ដារពលកម្មអន្តរជាតិ និងច្បាប់ជាតិ ក្នុងគ្រប់រោងចក្រផលិតសម្លៀកបំពាក់សម្រាប់នាំចេញ ស្របតាមកិច្ចព្រមព្រៀងនៅក្នុងអនុសារណៈជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា និងសមាគមន៍កាត់ដេរនៅកម្ពុជា។ កន្លងមក នៅឆ្នាំនេះ មានការវាយតម្លៃតាមប្រព័ន្ធអនឡាញ ក្នុងរោងចក្រចំនួន ១៩០ ។

លើសពីនេះ អង្គការសហប្រជាជាតិកំពុងធ្វើការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា វិស័យឯកជនរោងចក្រកាត់ដេរ និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលបង្កើនជំនាញពិសេសសម្រាប់កម្មការនីកាត់ដេរ ដោយប្រើប្រាស់ការអប់រំជាឧបករណ៍សម្រាប់បង្កើនភាពធន់របស់ពួកគេ ទៅនឹងវិបត្តិសេដ្ឋកិច្ច។ វគ្គ

បណ្តុះបណ្តាលនេះ មានគោលបំណងមិនត្រឹមតែបង្កើនជំនាញអក្ខរកម្ម និងជំនាញលេខនពន្ធ ជាមូលដ្ឋានរបស់កម្មករកាត់ដេរប៉ុណ្ណោះទេ ថែមទាំងបង្កើនចំណេះដឹងហិរញ្ញវត្ថុ និងការយល់ដឹងពីបញ្ហាសុខភាពបន្តពូជ អាហារូបត្ថម្ភ សិទ្ធិការងារ និងច្បាប់ការងារផងដែរ។ កម្មវិធីអក្ខរកម្មតាមរោងចក្រ (FLP) បានបន្តអនុវត្តក្នុងអំឡុងពេលដែលមានការរាតត្បាតជាសកលនៃជំងឺកូវីដ ១៩ និងបានផ្តល់ការអប់រំដល់កម្មករជាង ២000 នាក់ មកពីរោងចក្រដៃគូចំនួន ២៥ ក្នុងខេត្តចំនួន ១២ ។ កម្មវិធីនេះនឹងពង្រីកវិសាលភាពបន្ថែមទៀត ហើយនឹងត្រូវបន្តអនុវត្តរយៈពេល ៣ ឆ្នាំទៀត។

ការរាតត្បាតជាសកលនៃជំងឺកូវីដ ១៩ ផ្តល់នូវឱកាសកែលម្អលក្ខខណ្ឌនៅក្នុងវិស័យកាត់ដេរ និងជំរុញឱ្យមានការស្តារឡើងវិញប្រកបដោយចីរភាព ឆ្លើយតបចំពោះយេនឌ័រ និងឈរលើគោលការណ៍សិទ្ធិ។ អង្គការសហប្រជាជាតិលើកទឹកចិត្តឱ្យអាជ្ញាធរការពារសិទ្ធិជាមូលដ្ឋានរបស់កម្មករកាត់ដេរ ស្របតាមកាតព្វកិច្ចដែលមានចែងនៅក្នុងបទដ្ឋាននិងស្តង់ដារអន្តរជាតិស្តីពីសិទ្ធិមនុស្ស និងសិទ្ធិការងារ។ ការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលជំងឺកូវីដ-១៩ បង្កមកលើជីវភាពរស់នៅរបស់កម្មករកាត់ដេរ និងការពង្រឹងការប្រើប្រាស់យន្តការគាំពារសង្គមគួរត្រូវបានចាត់ទុកជាអាទិភាព។ វិធានការសមស្របនានា គួរផ្តោតលើការធានាសុខភាព និងសុវត្ថិភាពរបស់កម្មករកាត់ដេរ ទាំងក្នុងទាំងក្រៅ កន្លែងធ្វើការ។ យន្តការ និងគោលនយោបាយឆ្លើយតបចំពោះយេនឌ័រ ដែលអាចបំពេញតម្រូវការផ្សេងៗគ្នា របស់ស្ត្រី និងបុរស និងមនុស្សផ្សេងទៀតនៅក្នុងវិស័យនេះ កាន់តែមានប្រសិទ្ធភាព ក៏ជាអ្វីដែលចាំបាច់ត្រូវមានផងដែរ។ ប្រព័ន្ធអង្គការសហប្រជាជាតិនៅកម្ពុជា នៅតែបន្តប្តេជ្ញាធ្វើការងារជាមួយនឹងរដ្ឋាភិបាល នយោជក និងកម្មករនិយោជិតដើម្បីធានាថាឧស្សាហកម្មកាត់ដេរ កាន់តែមានចីរភាព និងកាន់តែធន់ទៅនឹងវិបត្តិនានា។

###

ឯកសារព័ត៌មានស្តីពីការឆ្លើយតបរបស់អង្គការសហប្រជាជាតិនៅកម្ពុជាចំពោះបញ្ហាកូវីដ-១៩ គឺជាឯកសារផ្លូវការដែលផលិតដោយអង្គការសហប្រជាជាតិនៅកម្ពុជា ដើម្បីផ្សព្វផ្សាយជូនអ្នកសារព័ត៌មាន និងដៃគូដទៃទៀត។ ឯកសារទាំងនេះត្រូវបានរៀបចំដោយការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងកញ្ញា កែវ ស្រីស្រស់ មន្ត្រីទំនាក់ទំនងនិងស្វែងរកការគាំទ្រនៃការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា តាមរយៈអ៊ីមែល៖ sreysros.keo@un.org។